# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## សុន្ទរកថា
**របស់លោកជំទាវ អ៊ុន សុគន្ធា លេខាធិការគណៈកម្មការ**
**មហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ នៃរដ្ឋសភា ក្នុងពិធីប្រកាសសម្ពោធ**
**ផ្សព្វផ្សាយសៀវភៅស្តីពី" ការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខ "**
**( ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៦ )**

-សូមគោរព ឯកឧត្តមបណ្ឌិត ង៉ួន ញ៉ិល អនុប្រធានទី២ រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា។

-សូមគោរពទូលថ្វាយសម្តេច នរោត្តម សិរីវុឌ្ឍ ឧត្តមទីប្រឹក្សាព្រះមហាក្សត្រ និងប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព។

-សូមគោរពលោកជំទាវ ឯកឧត្តម អស់លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីមេត្រី ។

ថ្ងៃនេះនាងខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយក្រៃលែងដែលត្រូវបានអញ្ជើញចូលរួមក្នុងពិធីប្រកាសសម្ពោធផ្សព្វផ្សាយសៀវភៅស្តីពី " ការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខ " នាពេលនេះ ។ក្នុងនាមសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមរូបនាងខ្ញុំផ្ទាល់ នាងខ្ញុំសូមសម្តែងនូវការស្វាគមន៍ដ៏កក់ក្តៅជាទីបំផុត ចំពោះអ្នកជំនាញការជាតិ ក៏ដូចអ្នកជំនាញការនៃសហភាពអន្តរសភា និងមជ្ឈមណ្ឌលប្រជាធិបតេយ្យសម្រាប់ការត្រួតពិនិត្យកងកម្លាំងប្រដាប់អាវុធ ដែលបានមកចែករំលែកនូវគោលការណ៍សំខាន់ៗ សម្រាប់ជំរុញការអនុវត្តន៍តួនាទី ភារកិច្ច របស់សមាជិកសភា ក្នុងការត្រួតពិនិត្យតាមដានលើវិស័យសន្តិសុខ ដែលមានក្នុងសៀវភៅនេះ ។

នាងខ្ញុំជឿជាក់ថា ឯកឧត្តម លោកជំទាវ លោក លោកស្រី ពិតជាមានការពេញចិត្តចំពោះសន្តិភាព សុវត្ថិភាព និងសេចក្តីសុខសាន្ត ដែលកើតឡើងពីការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លារបស់យើងទាំងអស់គ្នានៅក្នុងប្រទេសកម្ពុជា ពិសេសសម្មទ្ធិផលនៃការអនុវត្តន៍នយោបាយឈ្នះៗ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

សម្តេច លោកជំទាវ ឯកឧត្តម អស់លោក លោកស្រី ជាទីរាប់អាន

*ការឆ្ពោះទៅរកឯកភាពជាតិ និងសន្តិភាព

ជាទូទៅបើនិយាយពីវិស័យសន្តិសុខ យើងតែងតែនឹកដល់សន្តិសុខដែលពាក់ព័ន្ធតែលើផ្នែកកងទ័ពតែប៉ុណ្ណោះ ឬក៏សន្តិសុខរបស់ប្រទេសនីមួយៗ ក៏ប៉ុន្តែនៅក្នុងនិន្នាការបច្ចុប្បន្ន និង

ចរន្តពិតពលោក កាលណានិយាយដល់បញ្ហាសន្តិសុខ គឺសន្តិសុខដែលរាប់បញ្ចូលសមាសធាតុវិស័យ នយោបាយ សេដ្ឋកិច្ច និងសង្គម ។បើកំណត់ន័យឲ្យកាន់តែស៊ីជម្រៅទៀតក្នុងនិន្នាការសន្តិសុខបច្ចុប្បន្ន គឺសំដៅដល់សន្តិសុខដែលកើតមានចំពោះបុគ្គលម្នាក់ៗ នៅក្នុងសង្គម ។ស្ថិតក្នុងការយល់ឃើញបរិបទបែបនេះ កម្ពុជាបានកំណត់គោលការណ៍គ្រឹះសំខាន់ៗ នៅក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន។

កម្ពុជាពុះពារឧបសគ្គជាច្រើនដោយខ្លួនឯង ក្នុងការស្វែងរកសន្តិភាព ដំណោះស្រាយតាមរយៈការស្តាបនាទំនាក់ទំនងកិច្ចការផ្សេងៗជាមួយភាគីពាក់ព័ន្ធ ការបន្តសន្ទនាគ្នាក្រោមរូបភាពនៃការចរចារ ដោយឈរលើមូលដ្ឋាននៃស្មារតីមហាសាមគ្គីជាតិ និងឯកភាពជាតិ ក្នុងគោលដៅបង្រួបបង្រួមកម្លាំងប្រជាជាតិខ្មែរទាំងមូលជាធ្លុងមួយក្រោមបាវចនា "**ជាតិ សាសនា ព្រះមហាក្សត្រ** " តាមរយៈការអនុវត្តន៍ដោយជោគជ័យនូវនយោបាយ"**ឈ្នះ-ឈ្នះ**" ដែលផ្តួចផ្តើម និងដឹកនាំអនុវត្តដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបញ្ចប់ទាំងស្រុងនូវសង្គ្រាមស៊ីវិល ។

ផ្អែកលើបទពិសោធន៍ខាងលើ នាងខ្ញុំសូមគូសបញ្ជាក់ថា កម្ពុជាផ្តល់សារៈសំខាន់ដល់ការសន្ទនា ការចរចារ ការបង្រួបបង្រួម ការផ្សះផ្សារជាតិ នៅក្នុងក្របខណ្ឌផ្ទៃក្នុងជាតិ ប្រសើរជាងមានអន្តរាគមន៍ ឬការជ្រៀតជ្រែកពីខាងក្រៅ។កត្តាគន្លឹះនេះបានធ្វើឲ្យកម្ពុជាបញ្ចប់ជម្លោះប្រដាប់អាវុធដោយគ្មានការបង្ហូរឈាម ហើយនាំមកនូវការឯកភាពជាតិ ឯកភាពទឹកដី និងសន្តិភាពពេញលេញទូទាំងប្រទេស នាឆ្នាំ ១៩៩៨ ។

**សម្តេច លោកជំទាវ ឯកឧត្តម អស់លោក លោកស្រី**

***សន្តិភាព សន្តិសុខ និងតម្លាភាព ជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍គ្រប់វិស័យ**

ក្នុងរយៈពេលជិតពីរទសវត្សន៍នេះ កម្ពុជាបានបិទនូវទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតពីអតីតកាលរបស់ខ្លួន ហើយបានបោះជំហានទៅរកអនាគតមួយភ្លឺស្វាង ត្រចះត្រចង់ ក្រោមសន្តិភាព ស្ថិរភាព និងបានសមាហរណកម្មខ្លួនទៅក្នុងសហគមនអន្តរជាតិជាបន្តបន្ទាប់ ទាំងក្នុងក្របខណ្ឌទ្វេភាគី ទាំងពហុភាគី ។សន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខពេញលេញ បានធ្វើឲ្យសាធារណជនជាតិ អន្តរជាតិ មានជំនឿទុកចិត្តរឹងមាំ ពិសេសវិស័យឯកជនទាំងក្នុងស្រុក និងក្រៅស្រុក បានបោះទុនវិនិយោគរកស៊ីនៅកម្ពុជា បង្កជាកាលានុវត្តភាពសម្រាប់ប្រទេសកម្ពុជាអភិវឌ្ឍន៍លើគ្រប់វិស័យយ៉ាងឆាប់រហ័ស ដែលជំរុញឲ្យមានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យមប្រមាណ៧% ក្នុងរយៈពេលជាងមួយទសវត្សចុងក្រោយ និងបានកាត់បន្ថយភាពក្រីក្រជាង១% ក្នុង១ឆ្នាំ ព្រមទាំងបានក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក្នុងឆ្នាំ២០១៥ ។

អត្ថប្រយោជន៍ក្នុងដំណើរការសង្គមប្រជាធិបតេយ្យ សេរីពហុបក្ស ចាំបាច់ត្រូវមានការត្រួតពិនិត្យតាមដានរបស់ស្ថាប័ននីតិប្បញ្ញត្តិ ចំពោះការអនុវត្តន៍ច្បាប់របស់ស្ថាប័ននីតិប្រតិបត្តិ។ ការត្រួតពិនិត្យតាមដាននេះ រាប់បញ្ចូលទាំងការពិនិត្យតាមដានលើវិស័យសន្តិសុខ ដូចដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងលិខិតបទដ្ឋានគតិយុត្តិនានា។

***សម្តេច លោកជំទាវ ឯកឧត្តម អស់លោក លោកស្រី***

****ការផ្លោះទៅឯកភាពជាអន្តរជាតិ និងកិច្ចសហប្រតិបត្តការ ដើម្បីសន្តិភាព និងសន្តិសុខ***

មនុស្សជាតិកំពុងប្រឈមមុខនឹងតថភាពដ៏ជូរចត់នៃការកើតសង្គ្រាមថ្មីៗ សង្គ្រាមអូសបន្លាយ និងការកើតឡើងនៃអំពើភេរវកម្មដ៏សាហាវ ហើយក៏គ្មានប្រជាជាតិណាមួយចង់រស់នៅក្នុងស្ថានភាពអស្ថិរភាព និងអសន្តិសុខ ក្នុងពិភពលោកបែបនេះទេ ។ហេតុនេះទាមទារឲ្យថ្នាក់ដឹកនាំប្រទេសនីមួយៗ រកសន្តិភាព ស្ថិរភាព និងការពារឲ្យបានគង់វង្ស ដើម្បីប្រជាជនរបស់ខ្លួន ។

ជាការពិតណាស់ គេមិនអាចធ្វើឲ្យសម្រេចបាននូវផ្នែកខ្លះនៃសន្តិសុខ ដោយប្រទេសតែឯងបានទេ ចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការសន្តិសុខជាមួយប្រទេសនានា ។ម្យ៉ាងទៀត សកលភាវូបនីយកម្ម បានលើកកម្ពស់ភាពពឹងពាក់គ្នាទៅវិញទៅមករវាងប្រទេស និងប្រទេសនៅក្នុងវិស័យសន្តិសុខនេះផងដែរ ។

ជាទីបញ្ចប់នាងខ្ញុំសូមប្រសិទ្ធិពរជូន ដល់សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានវត្តមានក្នុងពិធីនេះ សូមប្រកបដោយជោគជ័យ សិរីសួរស្តី និងវិបុលសុខ កើតមានកុំបីឃ្លាងឃ្លៀតឡើយ ។

*សូមអរព្រះគុណ និងអរគុណ !*